**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០៦ សហវ.ប្រក.គរ

លិខិតចេញ

ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៧

រាជធានីភ្នំពេញ , ថ្ងៃទី៣១ ខែមករា ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពី

## ការកែសម្រួលអត្រាអាករនាំចេញឈើទំនិញមួយចំនួន

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យក្រមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជាលេខ ៥៧ ក្រ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៤៤ សហវ.ប្រក.គរ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០០៤
- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៧ លើលិខិតលេខ ០៧៥ សហវ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការចាំបាច់របស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច ៖

**ប្រការ ១៖** ត្រូវបានកែសម្រួល អត្រាអាករនាំចេញ ដប់ភាគរយ (១០%) លើមុខទំនិញគ្រួស និង ខ្សាច់ ដែលមានចែងនៅក្នុងតារាងពន្ធគយកម្ពុជាជាធរមាន និងមានលេខសម្គាល់ ទីតាំងរងលេខ **២៥០៥.១០.០០, ២៥០៥.៩០.០០, ២៥១៧.១០.១០,** និង ទីតាំងរងលេខ **២៥១៧.១០.៩០** ។

**ប្រការ ២៖** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣៖** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ព្រមទាំងអង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាបជាព័ត៌មាន "
- ទីចាត់ការគយ និងរដ្ឋាករ
- សភាពាណិជ្ជកម្មកម្ពុជា
  " ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត "
- ឯកសារ - កាលប្បវត្តិ